**សាលាដំបូងខេត្តតាកែវ**

<u>សំណុំរឿងព្រហ្មទណ្ឌ</u>

លេខ៧៧១

ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២០

<u>ជំនុំជម្រះ</u>

លេខ៥៨២

ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០២១

<u>សាលក្រមលើបណ្តឹងទាស់</u>

លេខ ៤៣ "ខ"

ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២២

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**តាមនាមប្រជារាស្ត្រខ្មែរ**

**តុលាការខេត្តតាកែវ**

បានបើកសវនាការជាសាធារណៈនៅបន្ទប់សវនាការ នៃសាលាដំបូងខេត្តតាកែវ នៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២២ ដោយមានសមាសភាពដូចតទៅ៖

**ចៅក្រមជំនុំជម្រះ**

លោកស្រី [redacted] ចៅក្រមសាលាដំបូងខេត្តតាកែវ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តតាកែវ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តតាកែវ

**ដើម្បីជំនុំជម្រះ**

**លើបណ្តឹងទាស់លេខ០៤/២០២២ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២២ ដែលមានជនជាប់ចោទ៖**

ឈ្មោះ [redacted] **ស្រីណុច** ភេទស្រី អាយុ២៥ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរលក់សម្លៀកបំពាក់ កម្រិតវប្បធម៌ថ្នាក់ទី១១ ទីកន្លែងកំណើតភូមិ[redacted] ខេត្តតាកែវ ទីលំនៅបច្ចុប្បន្ន [redacted] ខេត្តតាកែវ ឪពុកឈ្មោះ [redacted] **វ៉ែង** (រ) ម្តាយឈ្មោះ [redacted] **សារ៉ាត់** (រ) ប្តីឈ្មោះ [redacted]**លីណា** (រ) មានកូន០១នាក់ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការគ្មាន។ **(ក្រៅឃុំ)**

ជាប់ចោទពីបទ **ហិង្សាដោយចេតនា** ប្រព្រឹត្តនៅភូមិត្រាំខ្នារ ឃុំសូភី ស្រុកបាទី ខេត្តតាកែវ កាលពីថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០២០ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២១៧ នៃក្រមព្រហ្មទណ្ឌ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សុភ័ក្រលីតា** ភេទស្រី អាយុ២៥ឆ្នាំ ទីលំនៅបច្ចុប្បន្នភូមិត្រាំខ្នារ ឃុំសូភី ស្រុកបាទី ខេត្តតាកែវ។

លោកស្រី [redacted] ជាមេធាវីការពារផលប្រយោជន៍ឱ្យដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] **សុភ័ក្រលីតា**។

**-បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ៤០៦ ដសព ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងខេត្តតាកែវ។



Scanned with CamScanner

-**បានឃើញ** ដីកាដំណោះស្រាយលេខ៤៤៤/២១ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តតាកែវ។

-**បានឃើញ** ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ៥៨២ ដចត/២១ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០២១ របស់ប្រធានសាលាដំបូងខេត្តតាកែវ។

-**បានឃើញ** សាលក្រមព្រហ្មទណ្ឌលេខ១១៤ "ខ" ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តតាកែវ។

-**បានឃើញ** សេចក្តីចម្លងបណ្តឹងទាស់លេខ០៤/២០២២ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២២។

-**បានឃើញ** ឯកសារផ្សេងៗក្នុងសំណុំរឿងព្រហ្មទណ្ឌខាងលើ។

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០២០ នៅចំណុចផ្សារត្រាំខ្នារ ស្ថិតនៅភូមិត្រាំខ្នារ ឃុំសូភី ស្រុកបាទី ខេត្តតាកែវ ជនជាប់ចោទឈ្មោះ[redacted] **ស្រីណុច** បានវាយទះតប់ និងបោចសក់ទៅលើឈ្មោះ[redacted] **សុភ័ក្រលីតា** បណ្តាលឱ្យរងរបួសកកឈាមក្នុងកែវភ្នែក ខ្នាំពោះ ហើមច្រមុះ និងមានស្នាមរលាត់ដៃជើង ខណៈដែលជនរងគ្រោះដើរប្រមូលលុយចងការប្រាក់ក្នុងផ្សារត្រាំខ្នារ។ ក្រោយពេលកើតហេតុជនរងគ្រោះឈ្មោះ[redacted] **សុភ័ក្រលីតា** បានដាក់ពាក្យបណ្តឹងទៅសមត្ថកិច្ច ហើយសមត្ថកិច្ចបានកសាងសំណុំរឿងបញ្ជូនមកសាលាដំបូងខេត្តតាកែវដើម្បីចាត់ការតាមនីតិវិធី។ បន្ទាប់មកសាលាដំបូងខេត្តតាកែវ បានចេញសាលក្រមព្រហ្មទណ្ឌលេខ១១៤ "ខ" ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២១ ដោយកំបាំងមុខជនជាប់ចោទឈ្មោះ[redacted] **ស្រីណុច**។ ជនជាប់ចោទឈ្មោះ[redacted] **ស្រីណុច** បានប្តឹងទាស់នឹងសាលក្រមព្រហ្មទណ្ឌលេខ១១៤ "ខ" ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២១ ទើបសាលាដំបូងខេត្តតាកែវ បើកសវនាការជំនុំជម្រះលើបណ្តឹងទាស់របស់ជននេះ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ[redacted] **ស្រីណុច** បានឆ្លើយថា កន្លងមកខ្លួនមិនដែលស្គាល់ឈ្មោះ[redacted] **សុភ័ក្រលីតា** ទេ គឺទើបតែស្គាល់គ្នាមុនពេលខ្លួនមានរឿងជាមួយគាត់ប្រហែល០៥ខែប៉ុណ្ណោះ។ នៅថ្ងៃកើតហេតុខ្លួនបានវាយទៅលើឈ្មោះ[redacted] **សុភ័ក្រលីតា** ចំនួន០៣ដៃ ប៉ុន្តែមិនដឹងថាមានរបួស ឬអត់នោះទេ។ មូលហេតុដែលខ្លួនវាយឈ្មោះ[redacted]**ភ័ក្រលីតា** ព្រោះឈ្មោះនេះបានវាយមកលើខ្លួនមុន។ កន្លងមកខ្លួនក៏ធ្លាប់មានជម្លោះពាក្យសម្តីនឹងឈ្មោះ[redacted] **សុភ័ក្រលីតា** ម្តងដែរ ប៉ុន្តែមិនបានបង្កជាអំពើហិង្សាទេ។ ខ្លួនសូមបញ្ជាក់ថា ប្តីរបស់ខ្លួនឈ្មោះ[redacted]**ណា** ពីមុនមកគឺជាអតីតសង្សាររបស់ឈ្មោះ[redacted]**សុភ័ក្រលីតា**។ នៅថ្ងៃកើតហេតុខ្លួនបានប្រតាយប្រតប់ជាមួយនឹងឈ្មោះ[redacted]**សុភ័ក្រលីតា** ពិតមែន ប៉ុន្តែក្រោយមកក៏មានអ្នកលក់ដូរនៅផ្សារមកបំបែកពួកខ្លួនចេញពីគ្នា។ នៅថ្ងៃកើតហេតុឈ្មោះ[redacted] **សុភ័ក្រលីតា** វាយខ្លួនបណ្តាលឱ្យត្រូវរបួសត្រង់ក្បាលខ្លួន និងដៃ។



Scanned with CamScanner

-តាមអំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សុភ័ក្រលីតា** បានឆ្លើយថា កាលពីអំឡុងខែកុម្ភៈ និងខែមីនា ឈ្មោះ [redacted] **ស្រីណុច** ជាអាជីវករលក់ដូរក្នុងផ្សារ បាននិយាយបរិហាកេរ្តិ៍ខ្លួនថា ខ្លួនជាស្រីសំផឹងអស់សាច់ អ្នកណាក៏ដើរដេកជាមួយគេដែរ សូម្បីតែប្តីរបស់គាត់ក៏ដេកជាមួយដែរ។ ឈ្មោះ [redacted] **ស្រីណុច** បានដើរនិយាយក្នុងផ្សារត្រាំខ្នារ ឱ្យតែមានអ្នកណាមកទិញឥវ៉ាន់ គឺគាត់និយាយប្រាប់ទាំងអស់។ ក្រោយមកខ្លួនបានដាក់ពាក្យបណ្តឹងទៅប៉ុស្តិ៍នគរបាលរដ្ឋបាលសូភី ដើម្បីធ្វើការសម្របសម្រួល កុំឱ្យដើរនិយាយទៀត ប៉ុន្តែឈ្មោះ [redacted] **ស្រីណុច** នៅតែនិយាយដដែល។ នៅក្នុងអំឡុងខែកញ្ញា នៅពេលដែលខ្លួនទៅផ្សារទិញស្បែកជើង ឈ្មោះ [redacted] **ស្រីណុច** បានជេរមកលើខ្លួនថា មីសំផឹងអស់សាច់ អាណាក៏ដេកជាមួយដែរ សូម្បីតែប្តីគាត់ក៏ខ្លួនដេកជាមួយដែរ។ ពេលនោះខ្លួនមិនបានតបតអ្វីទេ រួចខ្លួនក៏ត្រឡប់មកផ្ទះវិញ។ ចំពោះការបរិហាកេរ្តិ៍នេះ គឺមានឈ្មោះ [redacted] **ញ៉ាញ់** គាតបានមកប្រាប់ខ្លួនថាឈ្មោះ [redacted] **ស្រីណុច** បានដើរនិយាយថា ខ្លួននេះមិនដឹងជាសណ្តានមកពីណាហើយថាម៉ែរបស់ខ្លួនចាញ់បោកប្រុសក្មេង និងជេរខ្លួនថាស្រីសំផឹងអស់សាច់ និងមានពាក្យអសុរសជាច្រើនទៀត។ ក្រោយមកម្តាយក្មេកខ្លួនបាននិយាយប្រាប់ប្តីខ្លួនថាគាត់ឮគេនិយាយប្រាប់ថា ឈ្មោះ [redacted] **ស្រីណុច** ដើរនិយាយអាក្រក់ពីខ្លួន។ នៅថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោងបី និងម្ភៃនាទីរសៀល ខ្លួនបានដើរប្រមូលលុយគេនៅផ្សារត្រាំខ្នារ ស្រាប់តែឈ្មោះ [redacted] **ស្រីណុច** បានដើរមកបុកស្មាខ្លួនយ៉ាងខ្លាំង ពេលនោះខ្លួនបានសួរគាត់ថា ម៉េចហែងមកបុកខ្ញុំអញ្ចឹង? បន្ទាប់មកឈ្មោះ [redacted] **ស្រីណុច** បានហក់វាយខ្លួន ដោយបោចសក់ខ្លួនទាញចូលក្នុងតូបគេ ហើយវាយខ្លួនយកតែម្តង។ ក្រោយមកប្រហែលប្រាំនាទី ឈ្មោះ [redacted] **ស្រីណុច** បានស្រែកហៅបងប្អូនរបស់គាត់ឈ្មោះ [redacted] **ស្រីនាថ** និងឈ្មោះ [redacted] **ឥន្ទា** ឱ្យមកជួយវាយខ្លួន ហើយពួកគេបានព្រួតវាយធ្វើបាបខ្លួន ដោយបានវាយច្រមុះរបស់ខ្លួន ព្រោះពួកគាត់ដឹងថាខ្លួនទើបតែធ្វើច្រមុះរួច និងធាក់រូបខ្លួនដោយពួកគាត់ដឹងថាខ្លួនទើបនឹងសម្រាលកូនរួចថ្មីៗ ហើយពេលនោះខ្លួនមិនបានតបតអ្វីឡើយ។ ចំពោះសកម្មភាពដែលពួកគាត់វាយធ្វើបាបខ្លួន គឺពួកគាត់ទាត់ ធាក់ ទះ និងបោចសក់ក្បាលខ្លួនទៅនឹងឥដ្ឋ។ លុះប្រហែលដប់នាទីក្រោយមកឈ្មោះ **រ៉ា** ជាអ្នកលក់នៅក្នុងផ្សារនោះដែរ បានមកជួយបំបែកចេញ ទើបខ្លួនអាចក្រោករួចហើយដើរចេញមកក្រៅផ្សារ ហើយប្តីរបស់ខ្លួនបានឌុបខ្លួនចេញពីផ្សារទៅប៉ុស្តិ៍នគរបាលដើម្បីដាក់ពាក្យបណ្តឹង។ បន្ទាប់មកខ្លួនបានទៅពេទ្យឃីហោ២៤ម៉ោង និងបានពិនិត្យឃើញថា ស្បូនមានឈាមកក ហើយខ្លួនបន្តទៅព្យាបាលនៅមន្ទីរពេទ្យរុស្ស៊ីនៅភ្នំពេញទាំងយប់ ដោយសារមិនស្រួលខ្លួនខ្លាំង រួចគ្រូពេទ្យបានដាក់សេរ៉ូមឱ្យរូបខ្លួន។ ក្នុងការព្យាបាលនេះខ្លួនមិនដឹងថាអស់ប៉ុន្មានទេ។ ខ្លួនសូមបញ្ជាក់អំពីរបួសក្រោយពីឈ្មោះ [redacted] **ស្រីណុច** ឈ្មោះ [redacted] **ស្រីនាថ** និងឈ្មោះ [redacted] **ឥន្ទា** វាយខ្លួនមានរងរបួសដូចជា ខ្ទាំពោះ ច្រមុះហើមខ្លាំង ឈាមកកក្នុងកែវភ្នែក ដៃជើងស្នាមជាំពាសពេញ ផ្ទៃមុខទាំងមូលហើមរលាត់កញ្ចឹងក ដោយសារស្នាមក្រចកខ្វាច ទងត្រចៀកដាច់សាច០១ដុំ បបូរមាត់បែកបន្តិច និងមានហូរ



Scanned with CamScanner

ឈាមតាមច្រមុះ និងមាត់។ ក្នុងរឿងនេះខ្លួនសូមទាមទារសំណងការខូចខាតចំនួនUSD២០,០០០ (ពីរម៉ឺនដុល្លារអាមេរិក) និងសុំឱ្យតុលាការផ្តន្ទាទោសតាមច្បាប់។

-តាមអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] **ស្រីនាថ** បានឆ្លើយថា កាលពីថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោងប្រហែលបី និងម្ភៃនាទីរសៀល មានអ្នកលក់ក្នុងផ្សារត្រាំខ្នារម្នាក់មកប្រាប់ខ្លួនថា មីអូនប្អូនឯងគេវាយហើយ ឮបែបនេះខ្លួនក៏ទៅហៅអ៊ីរបស់ខ្លួនឈ្មោះ [redacted] **គន្ធា** ទៅមើលពេលទៅដល់ ខ្លួនឃើញឈ្មោះ [redacted] **សុភ័ក្រលីតា** និងប្អូនរបស់ខ្លួនឈ្មោះ [redacted] **ស្រីណុច** កំពុងប្រតាយប្រតប់គ្នា ឃើញបែបនេះខ្លួនក៏ចូលទៅទាញដៃប្អូនខ្លួនឈ្មោះ [redacted] **ស្រីណុច** ចេញ ស្រាប់តែឈ្មោះ [redacted] **សុភ័ក្រលីតា** ហក់មករកវាយប្អូនខ្លួនទៀត។ ក្រោយពេលកើតហេតុប្អូនរបស់ខ្លួនឈ្មោះ [redacted] **ស្រីណុច** រងរបួសពកក្បាល ជាំដៃ និងដាច់រលាត់ត្រចៀក។ ខ្លួនសូមបញ្ជាក់ថា ពេលខ្លួន និងអ៊ីរបស់ខ្លួនឈ្មោះ [redacted] **គន្ធា** ទៅដល់តូបរបស់ឈ្មោះ [redacted] **សុភ័ក្រលីតា** ឈ្មោះនេះបានស្រែកហៅឱ្យប្អូនខ្លួនឈ្មោះ [redacted] **ស្រីណុច** ចុះមកវាយគ្នាជាមួយគាត់បង់លុយ រួចក៏មានការប្រតាយប្រតប់គ្នាតែម្តង។ ចំពោះរវាងឈ្មោះ [redacted] **សុភ័ក្រលីតា** និងឈ្មោះ [redacted] **ស្រីណុច** មានរឿងរ៉ាវឈ្លោះគ្នា និងនិយាយអាក្រក់ពីគ្នាទៅវិញទៅមកនោះ ខ្លួនមិនសូវដឹងច្បាស់នោះទេ។ នៅថ្ងៃកើតហេតុខ្លួនមិនដឹងថា អ្នកណាវាយអ្នកណាមុននោះទេ ខ្លួនគ្រាន់តែដឹងថា ពួកគេទាំងពីរមានរបួសទាំងសងខាង ហើយសម្រាប់ខ្លួន និងអ៊ីរបស់ខ្លួនឈ្មោះ [redacted] **គន្ធា** មិនបានព្រួតគ្នាវាយទៅលើឈ្មោះ [redacted] **សុភ័ក្រលីតា** នោះទេ។

-តាមអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] **គន្ធា** បានឆ្លើយថា កាលពីថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោងប្រហែលបី និងម្ភៃនាទីរសៀល ឈ្មោះ [redacted] **ស្រីណុច** បានមកប្រាប់ខ្លួនថា មានគេវាយឈ្មោះ [redacted] **ស្រីណុច** ហើយខ្លួនក៏រត់ទៅមើលជាមួយឈ្មោះ [redacted] **ស្រីនាថ** ពេលទៅដល់ ខ្លួនឃើញមានគេចាប់បំបែកឈ្មោះ [redacted] **ស្រីណុច** និងឈ្មោះ [redacted] **សុភ័ក្រលីតា**។ បន្ទាប់មកឈ្មោះ [redacted] **ស្រីណុច** ដើរមកតូបរបស់គាត់វិញ ស្រាប់តែឈ្មោះ [redacted] **សុភ័ក្រលីតា** ហក់មកវាយថែមទៀត ឃើញបែបនេះខ្លួនក៏និយាយថា ម៉េងអស្ចារ្យម៉េស គេឈប់វាយហើយ ម៉េងមកវាយគេទៀត បន្ទាប់មកឈ្មោះ [redacted] **សុភ័ក្រលីតា** បាននិយាយទៅកាន់ឈ្មោះ [redacted] **ស្រីណុច** ថា ម៉េងចុះមក អញវាយបង់លុយម្តង រួចខ្លួនបាននិយាយថា បានហើយ បន្ទាប់មកក៏មានគេមកឃាំងឈ្មោះ [redacted] **សុភ័ក្រលីតា** ជាប់កុំអីឈ្មោះនេះឡើងមកវាយឈ្មោះ [redacted] **ស្រីណុច** ទៀតហើយ ចំណែកខ្លួនមិនបានចូលរួមវាយទៅលើឈ្មោះ [redacted] **សុភ័ក្រលីតា** នោះទេ ព្រោះពេលទៅដល់គេបំបែកគ្នារួចទៅហើយ។ ក្រោយពេលកើតហេតុឈ្មោះ [redacted] ស្រីណុច រងរបួសពកក្បាល និងជាំដៃ។ ខ្លួនសូមបញ្ជាក់ថារវាងឈ្មោះ [redacted] **សុភ័ក្រលីតា** និងឈ្មោះ [redacted] **ស្រីណុច** មានរឿងឈ្លោះគ្នា និយាយអាក្រក់ពីគ្នាទៅវិញទៅមក រហូតដល់ថ្នាក់វាយគ្នាបែបនេះ ព្រោះឈ្មោះ [redacted] **សុភ័ក្រលីតា** ជាអតីតសង្សាចាស់ប្តីរបស់ឈ្មោះ [redacted] **ស្រីណុច** ហើយចេះតែដៀមដាមឌឺដងគ្នាទៅវិញទៅមករហូតដល់ថ្នាក់វាយគ្នានៅក្នុងផ្សារបែបនេះ។ ចំពោះរឿងរបស់ឈ្មោះ [redacted] **ស្រីណុច** និង



Scanned with CamScanner

ឈ្មោះ [redacted] **សុភ័ក្រលីតា** អ្នកវាយអ្នកណាមុនខ្លួនមិនដឹងនោះទេ ខ្លួនគ្រាន់តែដឹងថាមានរបួសទាំងសងខាង។ ក្នុងរឿងនេះខ្លួន និងឈ្មោះ [redacted] **ស្រីនាថ** មិនបានព្រួតគ្នាវាយទៅលើឈ្មោះ [redacted] **សុភ័ក្រលីតា** នោះទេ។

-តាមអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] **ផល្លា** បានឆ្លើយថា ខ្លួនធ្លាប់ស្គាល់ឈ្មោះ [redacted] **សុភ័ក្រលីតា** ឈ្មោះ [redacted] **ស្រីណុច** ឈ្មោះ [redacted] **ស្រីនាថ** និងឈ្មោះ [redacted] **ឥន្ទា** ព្រោះសុទ្ធតែជាអ្នកលក់ឥវ៉ាន់នៅក្នុងផ្សារត្រាំខ្នារដូចគ្នា គ្រាន់តែឈ្មោះ [redacted] **សុភ័ក្រលីតា** ស្និតស្នាលជាងអ្នកទាំងបីនាក់នោះ ប៉ុន្តែមិនត្រូវជាបងប្អូននឹងគ្នាទេ។ នៅថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០២០វេលាម៉ោងប្រហែលបីរសៀល ខ្លួនមិនបានមកលក់ខោអាវនោះទេ ព្រោះជាថ្ងៃខួបកំណើតកូនរបស់ខ្លួន ប៉ុន្តែខ្លួនបានមកផ្សារត្រាំខ្នារ ដើម្បីទិញឥវ៉ាន់ខួបកំណើតកូន ពេលកំពុងដើរផ្សារ ស្រាប់តែឮអ្នកផ្សារស្រែកថា មានគេវាយគ្នាៗ ឮបែបនេះខ្លួនបានដើរទៅរកមើល ពេលនោះខ្លួនក៏បានឃើញឈ្មោះ [redacted] **ស្រីណុច** ឈ្មោះ [redacted] **ស្រីនាថ** និងឈ្មោះ [redacted] **ឥន្ទា** កំពុងតែចោមរោមចាប់ឈ្មោះ [redacted] **សុភ័ក្រលីតា** ដោយឈ្មោះ [redacted] **ស្រីណុច** និងឈ្មោះ [redacted] **ស្រីនាថ** ចាប់បោចសក់របស់ឈ្មោះ [redacted] **សុភ័ក្រលីតា** ចំណែកឈ្មោះ [redacted] **ឥន្ទា** ពុំបានធ្វើសកម្មភាពអ្វីទេ ក្រោយមកក៏បែកគ្នាអស់ទៅ។ ក្រោយកើតហេតុខ្លួនឃើញឈ្មោះ [redacted] **សុភ័ក្រលីតា** បាក់ខ្ចង់ច្រមុះ។ ខ្លួនសូមបញ្ជាក់ថា នៅថ្ងៃកើតហេតុពេលខ្លួនឃើញសកម្មភាពនៃការវាយគ្នានោះ គឺជិតបញ្ចប់ទៅហើយដោយពុំបានឃើញពីសកម្មភាពនៃការវាយចម្រុះ ឬទាត់ទៅលើឈ្មោះ [redacted] **សុភ័ក្រលីតា** នោះទេ។

-លោកស្រី [redacted] ជាមេធាវីការពារផលប្រយោជន៍ឱ្យដើមបណ្តឹងរដ្ឋប្បវេណី បានធ្វើសេចក្តីសន្និដ្ឋានថា កូនក្តីរបស់ខ្លួនត្រូវបានជនជាប់ចោទឈ្មោះ [redacted] **ស្រីណុច** វាយធ្វើបាបបណ្តាលឱ្យរងរបួស និងមិនទាន់បានទទួលសំណងមកព្យាបាលរបួសនៅឡើយទេ ដូច្នេះក្នុងនាមខ្លួនជាមេធាវីការពារផលប្រយោជន៍ឱ្យដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំឱ្យតុលាការសម្រេចតម្កល់សាលក្រមលេខ១១៤ "ខ" ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២១ ទុកជាបានការដដែល។

**-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា** ក្រោយពីបានស្តាប់ចម្លើយ និងអំណានចម្លើយរបស់ភាគីពាក់ព័ន្ធ ព្រមទាំងបានពិនិត្យឯកសារដែលមាននៅក្នុងសំណុំរឿង ដូចនេះស្នើសុំឱ្យចៅក្រមជំនុំជម្រះតម្កល់សាលក្រមព្រហ្មទណ្ឌលេខ១១៤ "ខ" ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២១ ទុកជាបានការដដែល។

-ជនជាប់ចោទឈ្មោះ [redacted] **ស្រីណុច** បាននិយាយសម្តីចុងក្រោយថា ខ្លួនសូមឱ្យតុលាការមេត្តាជួយរកយុត្តិធម៌ដល់ខ្លួនផង។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់សាក្សី



Scanned with CamScanner

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារផលប្រយោជន៍ឱ្យដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យឯកសារ និងភស្តុតាងនានាក្នុងសំណុំរឿង

-ក្រោយពីបានពិនិត្យ ពិចារណាត្រឹមត្រូវតាមច្បាប់រួចហើយ។

## តុលាការខេត្តតាកែវ

## យល់ឃើញថា

១-ជនជាប់ចោទឈ្មោះ [redacted] **ស្រីណុច** បានប្តឹងទាស់ គឺស្ថិតនៅក្នុងអំឡុងដែលច្បាប់កំណត់ ហេតុនេះតុលាការអាចលើកយកសំណុំរឿងព្រហ្មទណ្ឌលេខ៧៧១ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២០ មកជំនុំជម្រះសារឡើងវិញ តាមបញ្ញត្តិមាត្រា៣៧១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-នៅក្នុងអំឡុងពេលជនជាប់ចោទមានសិទ្ធិប្តឹងទាស់លើសាលក្រមព្រហ្មទណ្ឌលេខ១១៤ "ខ" ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តតាកែវ ជនជាប់ចោទឈ្មោះ [redacted] **ស្រីណុច** បានប្តឹងទាស់លើសេចក្តីសម្រេចទាំងមូល នៃខ្លឹមសារនៃការផ្តន្ទាទោសរបស់ខ្លួន។ គប្បីតុលាការទទួលមកពិចារណា និងសម្រេចតាមបញ្ញត្តិច្បាប់ជាធរមាន។

៣-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **ស្រីណុច** ថាខ្លួនពិតជាបានវាយទៅលើឈ្មោះ [redacted] **សុភ័ក្រលីតា** ចំនួន០៣ដៃប្រាកដមែន ប៉ុន្តែមិនដឹងថាមានរបួសឬអត់នោះទេ? មូលហេតុដែលខ្លួនវាយឈ្មោះ [redacted] **សុភ័ក្រលីតា** ព្រោះឈ្មោះនេះបានវាយមកលើខ្លួនមុន។ ចម្លើយនេះមានភាពផ្ទុយគ្នានឹងអំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សុភ័ក្រលីតា** ថានៅថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោងបី និងម្ភៃនាទីរសៀល ខ្លួនបានដើរប្រមូលលុយគេនៅផ្សារត្រាំខ្នារ ស្រាប់តែឈ្មោះ [redacted] **ស្រីណុច** បានដើរមកបុកស្មាខ្លួនយ៉ាងខ្លាំង ពេលនោះខ្លួនបានសួរគាត់ថា ម៉េចហែងមកបុកខ្ញុំអញ្ចឹង? បន្ទាប់មកឈ្មោះ [redacted] **ស្រីណុច** បានហក់វាយខ្លួន ដោយបោចសក់ខ្លួនទាញចូលក្នុងតូបគេ ហើយវាយខ្លួនយកតែម្តង។ គប្បីតុលាការទទួលមកពិចារណា។

៤-តាមអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] **ស្រីនាថ** ថានៅថ្ងៃកើតហេតុខ្លួនបានឃើញឈ្មោះ [redacted] **សុភ័ក្រលីតា** កំពុងប្រតាយប្រតប់គ្នាជាមួយឈ្មោះ **សើ ស្រីណុច** ឃើញបែបនេះខ្លួនក៏ទាញដៃរបស់ឈ្មោះ [redacted] **ស្រីណុច** ចេញស្រាប់តែឈ្មោះ [redacted] **សុភ័ក្រលីតា** ហក់មកវាយឈ្មោះ [redacted] **ស្រីណុច** ថែមទៀត។ រីឯចម្លើយរបស់សាក្សីឈ្មោះ [redacted] **គន្ធា** ថានៅថ្ងៃកើតហេតុឈ្មោះ [redacted] **ស្រីនាថ** បានមកហៅខ្លួនទៅកន្លែងកើតហេតុជាមួយគ្នា ពេលទៅដល់ឈ្មោះ [redacted] **ស្រីណុច** និងឈ្មោះ [redacted] **សុភ័ក្រលីតា** ត្រូវបានគេចាប់បំបែកបាត់ទៅហើយ។ ចម្លើយទាំងនេះមិនមានមូលដ្ឋានគ្រប់គ្រាន់ឱ្យតុលាការជឿបានទេ ព្រោះចម្លើយរបស់សាក្សីឈ្មោះ [redacted] **ស្រីនាថ**



Scanned with CamScanner

និងឈ្មោះ [redacted] គន្ធា មានភាពផ្ទុយគ្នាត្រង់ឈ្មោះ [redacted] ស្រីនាថ បានអះអាងថាខ្លួនបានឃើញហេតុការណ៍វាយប្រតាយប្រតប់គ្នា រវាងឈ្មោះ [redacted] ស្រីណុច និងឈ្មោះ [redacted] សុភ័ក្រលីតា ប៉ុន្តែឈ្មោះ [redacted] គន្ធា បានអះអាងថាមិនបានឃើញហេតុការណ៍ប្រតាយប្រតប់គ្នានោះទេ ព្រោះពេលទៅដល់គេបំបែកគ្នាចេញអស់ហើយ ដែលសាក្សីទាំងពីររូបនេះ បានទៅកន្លែងហេតុដំណាលគ្នា ប៉ុន្តែបែរជាឃើញខុសគ្នាទៅវិញ។ ម្យ៉ាងវិញទៀតចំពោះសាក្សីឈ្មោះ [redacted] ស្រីនាថ គឺជាបងប្អូនបង្កើតរបស់ឈ្មោះ [redacted] ស្រីណុច ដែលជួយឆ្លើយដើម្បីឱ្យបានធូរស្រាលដល់ប្អូនរបស់ខ្លួនតែប៉ុណ្ណោះ។ ដូចនេះតាមអំណានចម្លើយរបស់សាក្សីទាំងនេះមិនអាចយកជាមូលដ្ឋានឱ្យតុលាការជឿបានទេ។

**៥**-តាមអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] **ផល្លា** ថានៅថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោងប្រហែលបីរសៀល ខ្លួនក៏បានឃើញឈ្មោះ [redacted] **ស្រីណុច** ឈ្មោះ [redacted] **ស្រីនាថ** និងឈ្មោះ [redacted] **គន្ធា** កំពុងតែចោមរោមចាប់ឈ្មោះ [redacted] **សុភ័ក្រលីតា** ដោយឈ្មោះ [redacted] **ស្រីណុច** និងឈ្មោះ [redacted] **ស្រីនាថ** ចាប់បោចសក់របស់ឈ្មោះ [redacted] **សុភ័ក្រលីតា** ចំណែកឈ្មោះ [redacted] **គន្ធា** ពុំបានធ្វើសកម្មភាពអ្វីទេ ក្រោយមកក៏បែកគ្នាអស់ទៅ។ គប្បីតុលាការទទួលមកពិចារណា។

**៦**-យល់ឃើញថាតាមអំណាចសាលក្រមព្រហ្មទណ្ឌលេខ១១៤ "ខ" ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តតាកែវ សម្រេចផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] **ស្រីណុច** ដាក់ពន្ធនាគារកំណត់០១ឆ្នាំ (មួយឆ្នាំ) ប៉ុន្តែទោសនេះត្រូវអនុវត្តទោសព្យួរ និងពិន័យជាប្រាក់ចំនួន២,០០០,០០០៛ (ពីរលានរៀល) ពីបទ**ហិង្សាដោយចេតនា** តាមបញ្ញត្តិមាត្រា២១៧ នៃក្រមព្រហ្មទណ្ឌ ព្រមទាំងបង្គាប់ឱ្យជនជាប់ចោទខាងលើសងចំណងជម្ងឺចិត្ត និងថ្លៃព្យាបាលរបួសចំនួន៨,០០០,០០០៛ (ប្រាំបីលានរៀល) ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សុភ័ក្រលីតា**។

**៧**-លោកស្រី [redacted] ជាមេធាវីការពារផលប្រយោជន៍ឱ្យដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើសេចក្តីសន្និដ្ឋានថា កូនក្តីរបស់ខ្លួនត្រូវបានជនជាប់ចោទឈ្មោះ [redacted] **ស្រីណុច** វាយធ្វើបាបបណ្តាលឱ្យរងរបួស និងមិនទាន់បានទទួលសំណងមកព្យាបាលរបួសនៅឡើយទេ ដូច្នេះក្នុងនាមខ្លួនជាមេធាវីការពារផលប្រយោជន៍ឱ្យដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំឱ្យតុលាការសម្រេចតម្កល់សាលក្រមលេខ១១៤ "ខ" ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២១ ទុកជាបានការដដែល។ គប្បីតុលាការទទួលមកពិចារណា។

**៨-សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការថា** ក្រោយពីបានស្តាប់ចម្លើយ និងអំណានចម្លើយរបស់ភាគីពាក់ព័ន្ធ ព្រមទាំងបានពិនិត្យឯកសារដែលមាននៅក្នុងសំណុំរឿង ដូចនេះស្នើសុំឱ្យចៅក្រមជំនុំជម្រះតម្កល់សាលក្រមព្រហ្មទណ្ឌលេខ១១៤ "ខ" ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២១ ទុកជាបានការដដែល។ គប្បីតុលាការទទួលមកពិចារណា។



Scanned with CamScanner

៩-សម្ដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] ស្រីណុច បានឆ្លើយថា ខ្លួនសូមឱ្យតុលាការមេត្តាជួយរកយុត្តិធម៌ដល់ខ្លួនផង។ គប្បីតុលាការទទួលមកពិចារណា។

១០-មានភស្តុតាង និងសាក្សីដាក់បន្ទុកគ្រប់គ្រាន់ដែលនាំឱ្យមានពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] ស្រីណុច ភេទស្រី អាយុ២៤ឆ្នាំ ពីបទ **ហិង្សាដោយចេតនា** ប្រព្រឹត្តនៅចំណុចផ្សារត្រាំខ្នារ ស្ថិតនៅភូមិត្រាំខ្នារ ឃុំសូភី ស្រុកបាទី ខេត្តតាកែវ កាលពីថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០២០ បទល្មើសដែលមានចែង និងផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា២១៧ នៃក្រមព្រហ្មទណ្ឌ។

## ហេតុដូច្នេះតុលាការ

## សម្រេចសេចក្ដី

១-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ១១៤ "ខ" ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តតាកែវ។

**២-សាលក្រមនេះ** ជំនុំជម្រះ និងប្រកាសជាសាធារណៈនៅសាលាដំបូងខេត្តតាកែវ នៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២២។

ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **ស្រីណុច** និងចំពោះមុខមេធាវីការពារផលប្រយោជន៍ឱ្យដើមបណ្ដឹងរដ្ឋប្បវេណី។

**ទុកសិទ្ធិប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់៕**

ថ្ងៃពុធ ៩កើត ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

តាកែវ,ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២២

**ក្រឡាបញ្ជីសវនាការ**

(ហត្ថលេខា និងត្រា)

[redacted]

**ចៅក្រមជំនុំជម្រះ**

(ហត្ថលេខា និងត្រា)

[redacted]

---

បានសម្រង់ចេញត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ៩កើត ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

តាកែវ,ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២២

**បានឃើញ**

**ចៅក្រមជំនុំជម្រះ**

[redacted]

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner